# សកម្មភាព មុខរបរ ឬអាជីវកម្ម
# ដែលត្រូវបានអនុញ្ញាតឱ្យបើកដំណើរការជាប្រក្រតីធម្មតា

(ប្រការ៣ថ្មី នៃសេចក្ដីសម្រេចលេខ ៥០ សសរ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាល)

## សកម្មភាព មុខរបរ ឬអាជីវកម្ម ដែលត្រូវបានអនុញ្ញាតឱ្យបើកដំណើរការជាប្រក្រតីធម្មតា

១. សកម្មភាពការងាររបស់កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ

២. រដ្ឋបាលថ្នាក់ក្រោមជាតិ

៣. សេវាសង្គ្រោះបន្ទាន់ សេវាសុខាភិបាល និងឱសថស្ថាន

៤. រោងចក្រ សហគ្រាស សិប្បកម្ម ឬទីកន្លែងផលិតម្ហូបអាហារនិងគ្រឿងឧបភោគបរិភោគ

៥. ទីសត្តឃាត

៦. រោងចក្រ សហគ្រាស សិប្បកម្ម ឬទីកន្លែងផលិតឱសថ និងសម្ភារៈបរិក្ខាពេទ្យ រួមទាំងម៉ាស អាកុល អុកស៊ីសែន

៧. សេវាពន្លត់អគ្គិភ័យ និងសេវាប្រមូល និងដឹកជញ្ជូនសំរាម-សំណល់រឹង

៨. ផ្សារលក់ដុំ និងផ្សារឬទីតាំងលក់ដូរគ្រឿងឧបភោគបរិភោគដែលមានសណ្ដាប់ធ្នាប់

៩. ស្ថានីយ៍ប្រេងឥន្ធនៈ-ហ្គាស និងទីតាំងលក់ហ្គាស

១០.សេវាកម្មដឹកជញ្ជូនម្ហូបអាហារ ឬគ្រឿងឧបភោគបរិភោគ (មិនត្រូវដឹកជញ្ជូនមនុស្សឡើយ)

១១.សេវាកម្មដឹកជញ្ជូនទំនិញទូទៅចេញ-ចូល ឬឆ្លងកាត់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ ដើម្បីបម្រើឱ្យវិស័យសង្គម-សេដ្ឋកិច្ច (មិនត្រូវដឹកជញ្ជូនមនុស្សឡើយ)

## ឯកសារសម្រាប់ធ្វើដំណើរមកបំពេញការងាររបស់បុគ្គលិកឯកជន

១. លិខិតអនុញ្ញាតធ្វើដំណើរដែលចេញដោយគណៈកម្មការប្រតិបត្តិនៃ គ.ប.ខ (ម្ចាស់អាជីវកម្មត្រូវរៀបចំស្នើសុំលិខិតអនុញ្ញាតធ្វើដំណើរទៅគណៈកម្មការប្រតិបត្តិនៃ គ.ប.ខ)

២. ឯកសារបញ្ជាក់អត្តសញ្ញាណ (អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន) និង

៣. លិខិតបញ្ជាក់ការងារដែលចេញដោយទីកន្លែងអាជីវកម្មពាក់ព័ន្ធ (ត្រូវកំណត់ច្បាស់លាស់អំពី ឈ្មោះ មុខងារ និងប្រភេទអាជីវកម្ម)។

## ឯកសារធ្វើដំណើរមកបំពេញការងាររបស់មន្ត្រីស្ថាប័នសាធារណៈ

១. ឯកសារបញ្ជាក់អត្តសញ្ញាណ (អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន) និង

២. លិខិតបញ្ជាបេសកកម្ម ចេញដោយក្រសួងស្ថាប័នសាមី។

រៀបចំដោយៈ ក្រសួងយុត្តិធម៌

# សកម្មភាព មុខរបរ ឬអាជីវកម្ម
# ដែលត្រូវកាត់បន្ថយចំនួនបុគ្គលិកឱ្យមកនៅត្រឹម ២%

(ប្រការ៣ថ្មី នៃសេចក្តីសម្រេចលេខ ៥០ សសរ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាល)

## សកម្មភាព មុខរបរ ឬអាជីវកម្ម ដែលត្រូវកាត់បន្ថយចំនួនបុគ្គលិកឱ្យមកនៅត្រឹម ២%

១. សកម្មភាពការងាររបស់ស្ថាប័នសាធារណៈ

២. សេវាផ្គត់ផ្គង់អគ្គិសនី, សេវាទឹកស្អាត និងសេវាកំពង់ផែ (លើកលែងចំពោះមន្ត្រី ឬបុគ្គលិកទទួលបន្ទុកខាងផ្នែកប្រតិបត្តិការ និងសង្វាក់ផលិតកម្ម ដែលអាចបំពេញការងារជាប្រក្រតីបាន)

៣. រាល់សកម្មភាពការងារ មុខរបរ ឬអាជីវកម្ម ដែលដំណើរការតាមរយៈប្រព័ន្ធអនឡាញ

៤. សេវាប្រៃសណីយ៍-ទូរគមនាគមន៍

៥. សេវាធនាគារ និងហិរញ្ញវត្ថុ

៦. សេវាកម្មសណ្ឋាគារ និងផ្ទះសំណាក់ (ត្រូវអនុវត្តគោលការណ៍អាហារថ្ងៃត្រង់នៅហ្នឹងកន្លែងបំពេញការងារ និងត្រូវស្នាក់នៅនៅហ្នឹងកន្លែងបំពេញការងារ)

## ឯកសារសម្រាប់ធ្វើដំណើរមកបំពេញការងាររបស់បុគ្គលិកឯកជន

១. លិខិតអនុញ្ញាតធ្វើដំណើរដែលចេញដោយគណៈកម្មការប្រតិបត្តិនៃ គ.ប.ខ (ម្ចាស់អាជីវកម្មត្រូវរៀបចំស្នើសុំលិខិតអនុញ្ញាតធ្វើដំណើរទៅគណៈកម្មការប្រតិបត្តិនៃ គ.ប.ខ)

២. ឯកសារបញ្ជាក់អត្តសញ្ញាណ (អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន) និង

៣. លិខិតបញ្ជាក់ការងារដែលចេញដោយទីកន្លែងអាជីវកម្មពាក់ព័ន្ធ (ត្រូវកំណត់ច្បាស់លាស់អំពីឈ្មោះ មុខងារ និងប្រភេទអាជីវកម្ម)។

## ឯកសារធ្វើដំណើរមកបំពេញការងាររបស់មន្ត្រីស្ថាប័នសាធារណៈ

១. ឯកសារបញ្ជាក់អត្តសញ្ញាណ (អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន) និង

២. លិខិតបញ្ជាបេសកកម្ម ចេញដោយក្រសួងស្ថាប័នសាមី។

រៀបចំដោយៈ ក្រសួងយុត្តិធម៌

# សកម្មភាព មុខរបរ ឬអាជីវកម្ម
# ដែលត្រូវមានការអនុញ្ញាត និងត្រូវអនុវត្តតាមការកំណត់
# របស់អាជ្ញាធរអនុវត្តវិធានការបិទខ្ទប់

(ប្រការ៣ថ្មី នៃសេចក្ដីសម្រេចលេខ ៥០ សសរ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាល)

## សកម្មភាព មុខរបរ ឬអាជីវកម្ម ដែលត្រូវមានការអនុញ្ញាត និងត្រូវអនុវត្តតាមការកំណត់របស់អាជ្ញាធរអនុវត្តវិធានការបិទខ្ទប់

១. ផ្សារម៉ាត និងភោជនីយដ្ឋាន-អាហារដ្ឋានដែលលក់ជាអាហារវេចខ្ចប់ (អាជ្ញាធរមានសមត្ថកិច្ចដែលអនុវត្តវិធានការបិទខ្ទប់ ត្រូវពិនិត្យ និងអនុញ្ញាតតាមការជាក់ស្ដែង)

២. ការដឹកជញ្ជូនបុគ្គលដែលបានបញ្ចប់ការធ្វើចត្តាឡីស័ក និងអ្នកជំងឺចេញពីមន្ទីរពេទ្យ ឬកន្លែងសម្រាកព្យាបាល (តាមការសម្របសម្រួលរបស់អាជ្ញាធរមានសមត្ថកិច្ច)

៣. សេវាកម្មសណ្ឋាគារ និងផ្ទះសំណាក់ដែលបម្រើឱ្យការធ្វើចត្តាឡីស័ក (ចំនួនបុគ្គលិក និងពេលម៉ោងធ្វើការរបស់បុគ្គលិកត្រូវកំណត់ដោយអាជ្ញាធរអនុវត្តវិធានការបិទខ្ទប់)

៤. បុគ្គលិកប្រចាំការ សម្រាប់គ្រប់គ្រង និងថែរក្សាឃ្លាំងស្ដុកទំនិញ ឬគ្រឿងឧបភោគបរិភោគ (ត្រូវអនុវត្តគោលការណ៍អាហារថ្ងៃត្រង់នៅហ្នឹងកន្លែងបំពេញការងារ និងត្រូវស្នាក់នៅនៅហ្នឹងកន្លែងបំពេញការងារ)

## ឯកសារសម្រាប់ធ្វើដំណើរមកបំពេញការងាររបស់បុគ្គលិកឯកជន

១. លិខិតអនុញ្ញាតធ្វើដំណើរដែលចេញដោយគណៈកម្មការប្រតិបត្តិនៃ គ.ប.ខ (ម្ចាស់អាជីវកម្មត្រូវរៀបចំស្នើសុំលិខិតអនុញ្ញាតធ្វើដំណើរទៅគណៈកម្មការប្រតិបត្តិនៃ គ.ប.ខ)

២. ឯកសារបញ្ជាក់អត្តសញ្ញាណ (អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន) និង

៣. លិខិតបញ្ជាក់ការងារដែលចេញដោយទីកន្លែងអាជីវកម្មពាក់ព័ន្ធ (ត្រូវកំណត់ច្បាស់លាស់អំពី ឈ្មោះ មុខងារ និងប្រភេទអាជីវកម្ម)។

រៀបចំដោយ៖ ក្រសួងយុត្តិធម៌